វ៉ុល២, លេខ២៥, ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០

# កូវីដ១៩៖ ជាមូលហេតុបណ្តាលឱ្យមានការផ្លាស់ប្តូរភូមិសាស្ត្រនយោបាយពិភពលោក?

លោកបណ្ឌិត អ៊ុន យាង*

នៅចុងបញ្ចប់នៃសង្គ្រាមលោកលើកទី២ សហរដ្ឋអាមេរិក បានដឹកនាំការបង្កើតសណ្តាប់ធ្នាប់អន្តរជាតិថ្មីមួយ ផ្តោតលើគោលការណ៍ទីផ្សារសេរី និងលទ្ធិប្រជាធិបតេយ្យសេរី ដែលត្រូវបានចាក់គ្រឹះយ៉ាងមាំ ដោយស្ថាប័នពហុភាគីមួយចំនួន។ សណ្តាប់ធ្នាប់អន្តរជាតិថ្មីនេះ មិនមែនសម្រេចឡើងដោយមិនមានការរារាំងណាមួយនោះឡើយ ព្រោះអតីតសហភាពសូវៀត និងសាធារណរដ្ឋប្រជាមានិតចិន បានដាក់វាំងននដែក (Iron Curtain) ដើម្បីជារនាំងរាំងស្ទះដល់ការរីកសាយភាយនៃប្រព័ន្ធនេះ។ ដោយមានភាពឯករាជ្យផ្នែកសេដ្ឋកិច្ច និងអវត្តមាននៃការលើកទឹកចិត្ត ប្រព័ន្ធសេដ្ឋកិច្ចផែនការ ដែលត្រូវបានគ្រប់គ្រងទាំងស្រុងដោយរដ្ឋនៅពីក្រោយវាំងននដែក បានបាត់បង់ជំហរ ហើយនៅទីបំផុតត្រូវដួលរលំ ដែលការណ៍នេះបានត្រួសត្រាយផ្លូវ សម្រាប់ជ័យជំនះរបស់អាមេរិក និងសណ្តាប់ធ្នាប់អន្តរជាតិបែបសេរីនិយមថ្មីមួយ ដឹកនាំដោយអាមេរិក។ ខណៈប្រទេសរុស្ស៊ី ដែលជាចំណែកសំខាន់បំផុត សល់ពីការដួលរលំចក្រភពសូវៀត បានទទួលយកដំបូន្មាន និងជំនួយពីលោកខាងលិច ប្រទេសចិន បានចាប់ផ្តើមទទួលយកប្រព័ន្ធសេដ្ឋកិច្ចមូលធននិយម យ៉ាងស្វាហាប់។ អនុត្តរភាពរបស់អាមេរិកមានឥទ្ធិពលយ៉ាងខ្លាំង ដែលសណ្តាប់ធ្នាប់សេរីនិយមថ្មីនេះ ត្រូវបានគេហៅថា ប្រព័ន្ធ "កុងសង់ស៊ីស វ៉ាស៊ីនតោន (Washington Consensus)"។ ភាពលេចធ្លោនៃសណ្តាប់ធ្នាប់សេរីនិយមថ្មី បានបង្កើតនូវការផ្លាស់ប្តូររចនាសម្ព័ន្ធមួយ ដែលបានជំរុញឱ្យលោក ហ្វ្រង់ស៊ីស ហ្វូគូយ៉ាម៉ា (Francis Fukuyama) ជឿ និងប្រកាសថានេះជា "ចុងបញ្ចប់នៃប្រវត្តិសាស្ត្រ"[1]។ ការសាទររបស់លោក ហ្វូគូយ៉ាម៉ា លើជ័យជំនះនៃលទ្ធិប្រជាធិបតេយ្យបែបថ្មីនេះ ពុំមានរយៈពេលយូរនោះឡើយ ពីព្រោះមិនបានយូរប៉ុន្មាន ប្រទេសចិន ក៏ចាប់ផ្តើមងើបឡើង។ ដោយទាញយកប្រយោជន៍ពីកំណើនសេដ្ឋកិច្ច ប្រកបដោយចីរភាព និងទុនបម្រុងហិរញ្ញវត្ថុដ៏ធំរបស់ខ្លួន ប្រទេសចិនបានពង្រីកឥទ្ធិពលរបស់ខ្លួនតាមរយៈជំនួយ និងការវិនិយោគនៅទូទាំងសាកលលោក សំដៅទៅរកឱកាស ដែលនាំឱ្យមានការផ្លាស់ប្តូរប្រព័ន្ធរបស់ពិភពលោកមួយ ដែលនឹងមកក្រោយបន្ទាប់ពីប្រព័ន្ធកុងសង់ស៊ីស វ៉ាស៊ីនតោន។ អំឡុងពេលប៉ុនប៉ងធ្វើការផ្លាស់ប្តូរសណ្តាប់ធ្នាប់ពិភពលោកនេះ ចិនបានផ្តល់គំរូជំនួសថ្មីមួយ ដែលមានឈ្មោះថា "កុងសង់ស៊ីស ប៉េកាំង (Beijing Consensus)"។ នៅពេលប្រឈមនឹងការកើនឡើងនៃអំណាច និងឥទ្ធិពលរបស់អំណាចថ្មី – ប្រទេសចិន – អនុត្តរអំណាចបច្ចុប្បន្ន – សហរដ្ឋអាមេរិក –មានក្តីព្រួយបារម្ភ និងមានភាពមិនច្បាស់អំពីអំណាច និងតួនាទីរបស់ខ្លួននៅក្នុងពិភពលោក ដែលកំពុងផ្លាស់ប្តូរ[2]។

---

[1] សូមមើល Francis Fukuyama, *The End of History and the Last Man.* (Simon and Schuster, 2006)។

[2] សូមមើល Graham Allison, *Destined for War: Can America and China Escape Thucydides's Trap?.* (Houghton Mifflin Harcourt, 2017)។

***លោកបណ្ឌិត អ៊ុន យាង** គឺជាសាស្ត្រាចារ្យរងផ្នែកវិទ្យាសាស្ត្រនយោបាយ នៅសាកលវិទ្យាល័យ Northern Illinois សហរដ្ឋអាមេរិក និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

© *រក្សាសិទ្ធដោយ មអក | ខ្លឹមសារនៃអត្ថបទនេះគឺជាគំនិតរបស់អ្នកនិពន្ធផ្ទាល់ និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា។*

ដូច្នេះ ការប្រកួតប្រជែងមនោគមវិជ្ជារវាងអាមេរិក និងចិន បានរីករាលដាលយ៉ាងខ្លាំង។ សហរដ្ឋអាមេរិក បង្ហាញថាគំរូរបស់ខ្លួន មានប្រសិទ្ធភាពក្នុងការលើកកម្ពស់ មិនត្រឹមតែសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យប៉ុណ្ណោះទេ ប៉ុន្តែទាំងលើកំណើនសេដ្ឋកិច្ចថែមទៀតផង។ បន្ទាប់ពីទទួលយកប្រព័ន្ធកុងសង់ស៊ីស វ៉ាស៊ីនតោន អស់រយៈពេលជាច្រើនទសវត្សរ៍មក ប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន កាត់បន្ថយភាពក្រីក្របានតែមួយកម្រិត និងបានឆ្ពោះទៅមុខតិចតួចប៉ុណ្ណោះក្នុងការអភិវឌ្ឍរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាព និងស្ថិរភាព[3]។ ផ្ទុយទៅវិញ ប្រទេសចិន តាមរយៈគំរូ កុងសង់ស៊ីស ប៉េកាំង របស់ខ្លួន សង្កត់ធ្ងន់ទៅលើកំណើនសេដ្ឋកិច្ច និងសណ្តាប់ធ្នាប់នយោបាយ។ ក្នុងរយៈពេលប៉ុន្មានឆ្នាំក្រោយនេះ ប្រទេសនេះ បានជួយជំរុញកំណើនសេដ្ឋកិច្ច របស់ប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនជាបន្តបន្ទាប់[4]។ ទោះជាយ៉ាងណាក្តី ការអនុវត្តប្រព័ន្ធកុងសង់ស៊ីស ប៉េកាំង ក៏មិនទាន់ផុតពីការសាកល្បង អំពីប្រសិទ្ធិភាពនៃប្រព័ន្ធនេះដែរ។ សាធារណជន និងអ្នកដឹកនាំនៅជុំវិញពិភពលោក បន្តសង្កេតមើលភាពដែលអាចអនុវត្តបាននៃគំរូរបស់ប្រទេសចិនមួយនេះ។ ជំងឺរាតត្បាតថ្មី មិនធ្លាប់មានពីមុន និងការឆ្លើយតបរបស់រដ្ឋាភិបាលចិន ក៏ដូចជាសហរដ្ឋអាមេរិក បានក្លាយជាការពិសោធលើប្រសិទ្ធិភាព និងសក្តិសិទ្ធភាពនៃគំរូកុងសង់ស៊ីស ប៉េកាំង និងគំរូកុងសង់ស៊ីស វ៉ាស៊ីនតោន។

ជំងឺរាតត្បាតកូវីដ១៩ ដែលដំបូងឡើយចេញមកពីទីក្រុងវូហាន ខេត្តហ៊ូប៉ីនៃប្រទេសចិន កាលពីចុងឆ្នាំមុន បានបង្កើតឱ្យមានការភ្ញាក់ផ្អើលនៅទូទាំងពិភពលោក។ បន្ទាប់ពីជួបឧបសគ្គដំបូងៗ ក្នុងការឆ្លើយតបទៅលើជំងឺរាតត្បាត ប្រទេសចិន បានចាត់វិធានការរហ័ស និងមានភាពស៊ីចង្វាក់ ដែលទទួលបានជោគជ័យក្នុងការទប់ស្កាត់ ការរីករាលដាលនៃជំងឺ ជាហេតុអនុញ្ញាតឱ្យរដ្ឋាភិបាលចិន អាចបើកប្រទេសជាធម្មតាវិញត្រឹមខែមីនា។ ភាពជោគជ័យរបស់ប្រទេសចិន បានបង្ហាញថា រដ្ឋាភិបាលផ្តាច់ការអាចមានសមត្ថភាពរឹងមាំ មិនត្រឹមតែក្នុងការជំរុញកំណើនសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងក្នុងការឆ្លើយតបទៅនឹងវិបត្តិផ្សេងៗផងដែរ។

នៅឯផ្នែកម្ខាងទៀតនៃមហាសមុទ្រប៉ាស៊ីហ្វិក សហរដ្ឋអាមេរិក ដែលជាមហាអំណាចពិភពលោកនាពេលបច្ចុប្បន្ន ហាក់ដូចជាមានភាពច្របូកច្របល់ មិនមានការរៀបចំ និងអសមត្ថភាពក្នុងការឆ្លើយតបទៅលើជំងឺរាតត្បាតកូវីដ១៩។ ការឆ្លើយតបមិនមានប្រសិទ្ធភាពរបស់រដ្ឋាភិបាលអាមេរិក បង្ហាញពីភាពផុយស្រួយនៃប្រព័ន្ធប្រជាធិបតេយ្យ ក្នុងពេលមានវិបត្តិ។ ដោយផ្តោតសំខាន់លើការឈ្នះឆ្នោតនាអាណត្តិបន្ទាប់ និងមិនខ្វល់ពីសុខុមាលភាពសង្គមក្នុងរយៈពេលវែង រដ្ឋបាលលោក ត្រាំ ហាក់ដូចជាកំពុងទោរទន់ ទៅតាមប្លុកសំឡេងឆ្នោតរបស់ខ្លួន ដែលមានលក្ខណៈចង្អៀត មិនមានទស្សនវិស័យវែងឆ្ងាយ មិនមានភាពពិតប្រាកដ និងមានការរើសអើសពូជសាសន៍។ ជាជាងជំរុញឱ្យមានការរួបរួម និងឯកភាពជាតិ ដើម្បីឆ្លើយតបនឹងការរីករាលដាលនៃជំងឺកូវីដ១៩ លោកប្រធានាធិបតី ត្រាំ បានព្យាយាមទម្លាក់កំហុសដាក់អ្នកដទៃ។ ដំបូងឡើយ លោកប្រធានាធិបតី ត្រាំ បានចាត់ទុកការព្រមានអំពីសក្តានុពលនៃជំងឺរាតត្បាតកូវីដ១៩ ថាជាការបោកបញ្ឆោត – ជាផែនការរបស់គណបក្សប្រជាធិបតេយ្យ ដើម្បីជះឥទ្ធិពលដល់ការបោះឆ្នោតឆ្នាំ២០២០ នៅអាមេរិក។ លោកប្រធានាធិបតី ត្រាំ និងអ្នកគាំទ្ររបស់លោក ចាត់ទុកការបិទប្រទេសថាជាការរំលោភលើសេរីភាពបុគ្គល។ ជាក់ស្តែង ពួកគេចាត់ទុកការបិទប្រទេសថាជាការរំលោភលើសិទ្ធិរដ្ឋធម្មនុញ្ញ របស់ប្រជាជន។ ខណៈដែលចំណាត់ការមានភាពយឺតយ៉ាវ និងបរាជ័យក្នុងការទប់ស្កាត់ជំងឺរាតត្បាត លោកប្រធានាធិបតី ត្រាំ បានកាន់តែបង្កើនយុទ្ធសាស្ត្រទម្លាក់កំហុសរបស់ខ្លួន រឹតតែខ្លាំងឡើងៗ។ ដំបូង លោកបានចោទប្រកាន់ចិន ចំពោះការលាក់បាំងភាពធ្ងន់ធ្ងរនៃជំងឺរាតត្បាត

[3] សូមមើល Dambisa Moyo, *Dead aid: Why Aid is Not Working and How There Is a Better Way for Africa.* (Macmillan, 2009)។

[4] សូមមើល Deborah Brautigam, *The Dragon's Gift: The Real Story of China in Africa.* (Oxford University Press, Oxford, 2011)។

កូវីដ១៩។ បន្ទាប់មក លោកបានចាត់ទុកជំងឺរាតត្បាតកូវីដ១៩ ថាជា "វីរុសចិន" ដោយភ្ជាប់ប្រភពដើមនៃវីរុសនេះ ជាមួយប្រទេសចិន សំដៅបន្ថែមទម្ងន់លើទ្រឹស្តី Conspiracy ដែលថាវីរុសនេះ ត្រូវបានផលិតនៅក្នុងមន្ទីរពិសោធន៍មួយក្នុងប្រទេសចិន។ ភាសារបស់រដ្ឋបាលលោក ត្រាំ គឺថាសហរដ្ឋអាមេរិក មិនត្រឹមតែរងការវាយប្រហារដោយវីរុសប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការវាយប្រហារពីចិនទៀតផង។ ភាសារបស់រដ្ឋបាលលោក ត្រាំ ទាក់ទងនឹងជំងឺរាតត្បាតកូវីដ១៩ ត្រូវបានគេមើលឃើញថា ជាផ្នែកមួយនៃការប៉ុនបងដើម្បីជាប់ឆ្នោតជាថ្មីម្តងទៀត និងជាផ្នែកមួយនៃការតស៊ូភូមិសាស្រ្តនយោបាយបន្ត ជាមួយនឹងចិន ដែលកំពុងតែមានឥទ្ធិពលកាន់តែខ្លាំងជាងមុន។ គេឃើញមានគំរូមុនៗ នៅក្នុងរដ្ឋបាលលោក ត្រាំ ដែលបានលាបពណ៌ប្រទេសចិន ថាជារដ្ឋដែលបំពានច្បាប់ (Rogue State)។ ផ្តើមពីយុទ្ធនាការឃោសនាបោះឆ្នោតឆ្នាំ២០១៦ លោក ត្រាំ ដែលពេលនោះជាបេក្ខភាពប្រធានាធិបតី បានសន្យាថានឹងផ្តួលប្រទេសចិនជាសត្រូវរបស់ខ្លួន ដែលបានធ្វើឱ្យខាតបង់ការងាររបស់ប្រជាជនអាមេរិក ឃ្លាំមើលអាជីវកម្មអាមេរិក និងលួចយកបច្ចេកវិទ្យាអាមេរិក[5]។ ជាថ្មីម្តងទៀត ខណៈរដូវកាលបោះឆ្នោតកាន់តែខិតជិតមកដល់ លោកប្រធានាធិបតី ត្រាំ បានយកបញ្ហាជំងឺរាតត្បាតកូវីដ១៩ ធ្វើជាបញ្ហានយោបាយ ដោយមិនត្រឹមតែចោទប្រកាន់ប្រទេសចិន ថាមិនត្រឹមតែលួចការងារ និងបច្ចេកវិទ្យាអាមេរិកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្លាប់ជនជាតិអាមេរិកទៀតផង។ ទ្រឹស្តី Conspiracy គឺជា ផ្នែកសំខាន់នៃមូលដ្ឋានចោទប្រកាន់របស់គាត់។

យោងតាមភស្តុតាងប្រវត្តិសាស្រ្ត ជំងឺរាតត្បាតបានជំរុញកិច្ចសហប្រតិបត្តិការអន្តរជាតិឱ្យកើនឡើង។ សហរដ្ឋអាមេរិក និងអតីតសហភាពសូវៀត បានសហការគ្នាប្រយុទ្ធនឹងជំងឺប៉ូលីអូ (Polio) នៅទូទាំងពិភពលោក។ គួរឱ្យកត់សម្គាល់ផងដែរ សហរដ្ឋអាមេរិក និងចិន បានសម្របសម្រួលគ្នាយ៉ាងជិតស្និទ្ធ ក្នុងអំឡុងពេលផ្ទុះជំងឺសារ (SARS) កាលពីឆ្នាំ២០០៣[6]។ ការគំរាមកំហែងផ្នែកសន្តិសុខមិនមែនប្រពៃណី ដូចជាជំងឺរាតត្បាតកូវីដ១៩ ទាមទារឱ្យមានការសហការទូលំទូលាយ ដែលមិនមែនត្រឹមតែរដ្ឋាភិបាលប៉ុណ្ណោះទេ ប៉ុន្តែត្រូវរួមបញ្ចូលទាំងអង្គការពហុភាគី និងអង្គការមិនមែនរដ្ឋាភិបាលផងដែរ។ សហរដ្ឋអាមេរិក បានចៀសវាងនូវយន្តការពហុភាគីទាំងនេះ។ អ្វីដែលគួរឱ្យភ្ញាក់ផ្អើលនោះ នៅក្រោមទម្ងន់នៃជំងឺកូវីដ១៩ សហរដ្ឋអាមេរិក មិនត្រឹមតែបានវាយប្រហារប្រទេសចិនប៉ុណ្ណោះទេ ប៉ុន្តែក៏បានចោទប្រកាន់ ទៅលើអង្គការសុខភាពពិភពលោក ថាបានបំភាន់ពិភពលោក អំពីទំហំនៃការបំផ្លិចបំផ្លាញរបស់ជំងឺរាតត្បាតកូវីដ១៩ ដើម្បីលាក់បាំងការទទួលខុសត្រូវរបស់ ចិន។ ហេតុនេះ សហរដ្ឋអាមេរិក បានសម្រេចដកវិភាគទានរបស់ខ្លួន ទៅកាន់អង្គការសុខភាពពិភពលោកភ្លាមៗ។ លើសពីនេះ សហរដ្ឋអាមេរិក មិនត្រឹមតែបរាជ័យ ក្នុងការសម្របសម្រួលជាមួយសម្ព័ន្ធមិត្តអឺរ៉ុប ក្នុងកិច្ចប្រឹងប្រែងមួយដើម្បីប្រយុទ្ធនឹងជំងឺរាតត្បាតនេះទេ ប៉ុន្តែថែមទាំងបានប្រកួតប្រជែងជាមួយសម្ព័ន្ធមិត្តខ្លួន សម្រាប់ការផ្គត់ផ្គង់ផ្នែកវេជ្ជសាស្រ្តសំខាន់ៗទៀតផង។

ស្របពេលដែលសហរដ្ឋអាមេរិក បានប្រកាន់យកគោលនយោបាយការបរទេសឯកោនិយម ប្រទេសចិនបានអនុវត្តគោលការណ៍ពហុភាគី ដើម្បីដោះស្រាយជំងឺរាតត្បាតនេះ។ ឆ្លើយតបទៅនឹងការប្រកាសរបស់សហរដ្ឋអាមេរិក ដែលថានឹងពន្យារពេលផ្តល់វិភាគទានរបស់ខ្លួនដល់ អង្គការសុខភាពពិភពលោក ប្រទេសចិន បានបង្កើនថវិកាវិភាគទានរបស់ខ្លួន

[5] សូមមើល David Jackson and Kim Hjelmgaard, "Trump Says US Investigating Whether Coronavirus Spread After China Lab Mishap but Cites No Evidence," *USA Today*, April 20, 2020. Available at: https://www.usatoday.com/story/news/world/2020/04/18/trump-us-investigating-whether-coronavirus-spread-china-lab/5158551002/។

[6] សូមមើល Yanzhong Huang, "The US and China Could Cooperate to Defeat the Pandemic: Instead, their Antagonism Makes Matters Worse," *Foreign Affairs*, March 24, 2020. Available at: https://www.foreignaffairs.com/articles/china/2020-03-24/us-and-china-could-cooperate-defeat-pandemic។

ជូនដល់អង្គការនេះទៅវិញ។ កាយវិការរបស់ប្រទេសចិន បង្ហាញពីការប៉ុនប៉ង ដើម្បីបញ្ជ្រាបឥទ្ធិពលរបស់ខ្លួននៅក្នុងស្ថាប័នអន្តរជាតិ។

ជាការភ្ញាក់ផ្អើលរបស់អ្នកសង្កេតការណ៍ជាច្រើន ដែលសហរដ្ឋអាមេរិក ត្រូវបានគេរាយការណ៍ ថាបានបង្វែរការដឹកជញ្ជូនម៉ាស និងឧបករណ៍វេជ្ជសាស្ត្រផ្សេងៗ ពីប្រទេសសម្ព័ន្ធមិត្តដូចជាកាណាដា និងបារាំង។ អាកប្បកិរិយា "America First" បែបនេះ បានធ្វើឱ្យមានការសង្ស័យ និងចោទជាសំណួរថាតើសហរដ្ឋអាមេរិក អាចជឿទុកចិត្តបានកម្រិតណា ក្នុងនាមជាសម្ព័ន្ធមិត្ត ហើយនេះមិនទាន់និយាយ ក្នុងនាមជាមេដឹកនាំពិភពលោក នៅអំឡុងពេលមានវិបត្តិផង។ ផ្ទុយទៅវិញ នៅកន្លែងផ្សេងទៀតនៅជុំវិញពិភពលោក ប្រទេសចិនបានខិតខំប្រឹងប្រែងយ៉ាងក្លៀវក្លាក្នុងបេសកកម្ម "នយោបាយការទូតម៉ាស" (Face Mask Diplomacy) ដោយបញ្ជូនអ្នកជំនាញ និងសម្ភារវេជ្ជសាស្ត្រ ទៅប្រទេសដែលកំពុងតែត្រូវការ។ វិសាលភាពនៃ "នយោបាយការទូតម៉ាស" របស់ចិន អាចមើលឃើញយ៉ាងច្បាស់។ ឧទាហរណ៍ នៅតំបន់អាស៊ីអាគ្នេយ៍ វិធីសាស្ត្រសហប្រតិបត្តិការរបស់ចិន បានផ្លាស់ប្តូរឥរិយាបថ មេដឹកនាំ និងសាធារណជនក្នុងតំបន់ មកលើប្រទេសចិន។ ការពង្រីកឥទ្ធិពលក្រៅប្រទេសរបស់ចិន តាមរយៈគំនិតផ្តួចផ្តើមផ្លូវមួយ ខ្សែក្រវ៉ាត់មួយ ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ បានបង្កើតឱ្យមានទស្សនៈអវិជ្ជមាន នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ ការវិនិយោគរបស់ចិន នៅក្នុងប្រទេសនានា ដូចជាកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា បានធ្វើឱ្យមានការរិះគន់ជាសាធារណៈ ទៅលើប្រទេសចិន ថាជាការបម្រើប្រយោជន៍ចិនខ្លួនឯង។ រូបភាពអវិជ្ជមានក្នុងចំណោមសាធារណជន នៅក្នុងបណ្តាប្រទេសអាស៊ីអាគ្នេយ៍ទៅកាន់ប្រទេសចិន បានរសាត់ទៅយ៉ាងលឿន នៅពេលដែលព័ត៌មានអំពីការដឹកជញ្ជូនសម្ភារផ្គត់ផ្គង់វេជ្ជសាស្ត្រ និងវត្តមានរបស់បុគ្គលិកពេទ្យចិន មកកាន់ប្រទេសទាំងនេះ បានលេចដំណឹងឡើងជាបន្តបន្ទាប់។ ចំណាប់អារម្មណ៍វិជ្ជមាន អំពីបំណងល្អរបស់ប្រទេសចិន កើតមានឡើងនៅផ្នែកជាច្រើននៃពិភពលោក គឺជារឿងធម្មតានៅចំពោះមុខស្ថានការណ៍ធ្ងន់ធ្ងរបែបនេះ ដែលសាធារណជនទូទៅ មានការភ័យខ្លាច ហើយរដ្ឋាភិបាលមានសមត្ថភាពតិចតួច ក្នុងការប្រយុទ្ធនឹងជំងឺរាតត្បាត។ សរុបមក "នយោបាយការទូតម៉ាស" របស់ចិន បង្ហាញទៅកាន់មេដឹកនាំ និងសាធារណជន នៅផ្នែកជាច្រើននៃពិភពលោក ថាការកើនឡើងឥទ្ធិពលនៃប្រទេសចិន គឺជាអំណាចដ៏សមស្រប (Benign Power)។

គួរឱ្យចាប់អារម្មណ៍ក្នុងការកត់សម្គាល់ផងដែរថា សាធារណជន និងមេដឹកនាំនៅទូទាំងពិភពលោក បានឃើញពីគុណសម្បត្តិនៃគំរូរបស់ចិន ដែលសង្កត់ធ្ងន់លើភាពចាំបាច់នៃប្រសិទ្ធភាព និងសក្តិសិទ្ធភាពរបស់ការដឹកនាំបែបផ្តាច់ការនិយម។ គំរូរបស់ប្រទេសចិន មិនត្រឹមតែបង្ហាញពីភាពជោគជ័យក្នុងការជំរុញកំណើនសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែវាក៏មានប្រសិទ្ធភាពផងដែរក្នុងការប្រយុទ្ធនឹងវិបត្តិ ដូចជាជំងឺរាតត្បាតកូវីដ ១៩នេះ។ ក្នុងពេលជាមួយគ្នានេះដែរ សាធារណជន និងថ្នាក់ដឹកនាំ បានចោទសួរពីភាពសក្តិសមនៃគំរូរបស់អាមេរិក ក្នុងការដោះស្រាយវិបត្តិ។ ផ្ទុយទៅវិញ ពួកគេចាត់ទុកគំរូរបស់អាមេរិកថាមានភាពបែកបាក់ គ្មានលក្ខណៈសម្រេចដាក់លាក់ គ្មានប្រសិទ្ធភាព និងគ្មានវិន័យត្រឹមត្រូវក្នុងការគ្រប់គ្រង។

ចាប់តាំងពីក្លាយជាមហាអំណាចសេដ្ឋកិច្ចពិភពលោកមក ចិនបានតាំងខ្លួនជាមេដឹកនាំពិភពលោក។ ក្នុងសមាជគណបក្សនៅឆ្នាំ២០១៧ លោក ស៊ី ជីងពីង បានព្យាករថា ប្រទេសចិននឹងក្លាយជាមហាអំណាចពិភពលោក នៅឆ្នាំ២០៥០។ ជំងឺរាតត្បាតកូវីដ១៩ ពិតជាបានរុញច្រានប្រទេសចិន ខិតទៅជិតគោលដៅនោះ បានមួយជំហានបន្ថែមទៀតពិតប្រាកដមែន។ "នយោបាយការទូតម៉ាស់" និងភាពជោគជ័យរបស់ខ្លួន ក្នុងការទប់ស្កាត់ជំងឺរាតត្បាតកូវីដ១៩ បានធ្វើឱ្យគំរូរបស់ចិនកាន់តែមានភាពទាក់ទាញ ដល់ប្រទេសកំពុងអភិវឌ្ឍន៍ជាងពេលណាៗទាំងអស់។ ការអភិវឌ្ឍទាំងនេះ ផ្តល់ឱ្យប្រទេសចិននូវអំណាចទន់ (Soft Power) បន្ថែម ដែលជាធាតុផ្សំដ៏សំខាន់មួយសម្រាប់ប្រទេសចិន ក្នុងការបញ្ជ្រាបឥទ្ធិពលជាសាកលរបស់ខ្លួន។

ដោយមានចំណាប់អារម្មណ៍ជាវិជ្ជមាន លើគំរូរបស់ប្រទេសចិន បន្ទាប់ពីការរីករាលដាលនៃជំងឺរាតត្បាតកូវីដ១៩ គួបផ្សំនឹងភាពមន្ទិលសង្ស័យរបស់ប្រទេសលោកខាងលិច មកកាន់ចិន វាជាការចាំបាច់ដែលចិនព្យាយាមពង្រឹងជំហររបស់ខ្លួនបន្ថែមទៀត នៅក្នុងប្រព័ន្ធពិភពលោក។ ការប៉ុនប៉ងបែបនេះរបស់ចិន ប្រាកដជាប្រឈមនឹងប្រតិកម្មប្រឆាំងមកវិញ ពីសំណាក់សហរដ្ឋអាមេរិក និងសហភាពអឺរ៉ុបជាមិនខាន។ បន្ទាប់ពីស្ថានការណ៍ត្រលប់ជាស្ងប់ស្ងាត់វិញ ល្បឿន និងវិសាលភាពនៃការបញ្ជ្រាបអំណាចរបស់ចិន នឹងពឹងផ្អែកលើភាពជោគជ័យនៃការស្តារសេដ្ឋកិច្ចឡើងវិញនៅក្នុងប្រទេសចិន នៅសហរដ្ឋអាមេរិក និងនៅប្រទេសលោកខាងលិចសំខាន់ៗដទៃទៀត។ អ្វីដែលប្រាកដនោះគឺថា គំរូ កុងសង់ស៊ីស ប៉េកាំង នឹងបន្តប្រកួតប្រជែងគំរូ កុងសង់ស៊ីស វ៉ាស៊ីនតោន សម្រាប់អនាគតដ៏ឆាប់មួយ ដែលកម្លាំងស្របការផ្លាស់ប្តូរ និងកម្លាំងប្រឆាំងការផ្លាស់ប្តូរ នឹងកែប្រែរចនាសម្ព័ន្ធភូមិសាស្ត្រនយោបាយ បច្ចុប្បន្នក្នុងថ្ងៃណាមួយជាក់ជាមិនខាន។

**អ្នកនិពន្ធជ្រើសយកការប្រើនិទ្ទេសជើងទំព័រសម្រាប់ឯកសារយោង។*

Cambodia Development Center

Cambodia Development Center (@cd.centerkh)

Cambodia Development Center

Building E, University of Puthisastra, #55, Street 184, Sangkat Boeung Raing, Khan Daun Penh

info@cd-center.com | (+855) 10 950 456

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center